៧-វរសេនីយ៍ទោ **ស៊ិន លី** អត្តលេខ ០១៧៥៣៦ មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

៨-វរសេនីយ៍ត្រី **ចាន់ មាន** អត្តលេខ ០៤៦៨៧៩ អនុប្រធានមន្ទីរផែនការប្រតិបត្តិការ កងរាជអាវុធហត្ថខេត្តកំពង់ធំទឹកប្រាក់ចំនួន ១១.២៦៦ ដុល្លារ

៩-វរសេនីយ៍ត្រី **វ៉ាន់ ម៉ាក់** អត្តលេខ ០១២៥៦៨ អនុប្រធានមន្ទីរប្រេកពកម្លាំងកងរាជ អាវុធហត្ថ ខេត្តឧត្តរមានជ័យ ទឹកប្រាក់ចំនួន ១១.១៥០ ដុល្លារ

១០-វរសេនីយ៍ត្រី **ទូ សុគន្ធ** អត្តលេខ ០៤៦៨៦៨ អនុប្រធានមន្ទីរផែនការប្រតិបត្តិការ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

១១-វរសេនីយ៍ត្រី **ហាម សុខសាន្ត** អត្តលេខ ០២០៥៦៨ អនុប្រធានមន្ទីរស្រាវជ្រាវនិងយុត្តិធម៌ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

១២-អនុសេនីយ៍ឯក **សួន វណ្ណា** អត្តលេខ ១៤៨៩៥៦ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថ ក្រុងសំរោងខេត្តឧត្តរមានជ័យ ទឹកប្រាក់ចំនួន ១១.១៣០ ដុល្លារ

១៣-អនុសេនីយ៍ឯក **ឌុច គឹមសេង** អត្តលេខ ០២០៦៩៥ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថ ស្រុកចុងកាល់ខេត្តឧត្តរមានជ័យ ទឹកប្រាក់ចំនួន ១១.១១៥ ដុល្លារ

១៤-អនុសេនីយ៍ឯក **គង់ សំណាង** អត្តលេខ ០៣៦៤៧៥ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថ ស្រុកបន្ទាយអំពិលខេត្តឧត្តរមានជ័យ ទឹកប្រាក់ចំនួន ១១.១១០ ដុល្លារ

១៥-អនុសេនីយ៍ឯក **ហ៊ីត សីហា** អត្តលេខ ០៤៦៩១០ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថ ក្រុងព្រះសីហនុ ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

១៦-អនុសេនីយ៍ឯក **សំរិទ្ធ មុន្នី** អត្តលេខ ០៣៦២៤០ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថ ស្រុកស្រីស្នំខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

១៧-អនុសេនីយ៍ឯក **ជា ណុល** អត្តលេខ ០៦០២៧០ នាយរដ្ឋបាលសរុបមន្ទីរភស្តុភារបច្ចេកទេស កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

១៨-អនុសេនីយ៍ឯក **ហាក់ សេង** អត្តលេខ ១៦៧៤១០ នាយរដ្ឋបាលសរុបមន្ទីរស្រាវជ្រាវនិង យុត្តិធម៌កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

១៩-លោក **ម៉ៅ ធឿង** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

២០-លោក **អ៊ន់ តាំងឡៃ** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ
២១-លោក **លី សាឌុន** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ
២២-លោក **ហ៊ូ សៀកផេង** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ
២៣-លោក **ហ៊ុយ គៀង** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ
២៤-លោក **លី កងឆេង** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ
២៥-លោកស្រី **កង ស្រិន** អាជីវករខេត្តសៀមរាប ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

១-អនុសេនីយ៍ឯក **ស៊ឹម សុធា** អត្តលេខ ០៣៦៤៤៨ ប្រធានស្នាក់ការសន្តិសុខ ៦៧១ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

២-អនុសេនីយ៍ឯក **អ៊ឹម មុន្នី** អត្តលេខ ១៩៧០៧៨ ប្រធានស្នាក់ការសន្តិសុខ៦០៧ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

៣-អនុសេនីយ៍ឯក **ហេង ទិចិត្រ** អត្តលេខ ១៩៧០៧៣ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថ ស្រុកជីក្រែងខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

៤-អនុសេនីយ៍ឯក **មាស សារុំ** អត្តលេខ ១៩៧០០៦ នាយរដ្ឋបាលសរុបមន្ទីរប្រេភពកម្លាំង កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

៥-អនុសេនីយ៍ឯក **ឆ ច័ន្ទនិច** អត្តលេខ ០៣៥៨០៣ ជំនួយការការិយាល័យសន្តិសុខ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

៦-អនុសេនីយ៍ឯក **មាស រិទ្ធិស័ក្ត** អត្តលេខ ០៣៩៧៧០ ប្រធានស្នាក់ការសន្តិសុខ៦០៩ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

៧-អនុសេនីយ៍ឯក **ញឹម ធីរៈ** អត្តលេខ ១៩៦៣៦០ នាយការិយាល័យ ស្រាវជ្រាវប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

៨-អនុសេនីយ៍ឯក **សេង សុជាតិ** អត្តលេខ ០២៩៩៣៩ ជំនួយការ សេនាធិការ កងរាជអាវុធហត្ថ ខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ៦.៥០០ដុល្លារ

៩-អនុសេនីយ៍ឯក **លន់ សំណាង** អត្តលេខ ០២៣៤០៩ នាយរងលេខាធិការដ្ឋានស្នងការដ្ឋាន ប្រភពកម្លាំង ទឹកប្រាក់ចំនួន ៥.២០០ ដុល្លារ

១០-អនុសេនីយ៍ឯក **គិត ឆាយ** អត្តលេខ ០២៣៣៦០ អនុប្រធានមន្ទីរភស្តុភារបច្ចេកទេស កងរាជអាវុធហត្ថខេត្តព្រះសីហនុ ទឹកប្រាក់ចំនួន ៥.៥០០ ដុល្លារ

១១-អនុសេនីយ៍ទោ **ផល នឹមណាន** អត្តលេខ ១០៥៦០០ ប្រធានស្នាក់ការសន្តិសុខB៤-២ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១២-អនុសេនីយ៍ទោ **ហ៊ឹម លីភិន** អត្តលេខ ០៣៦២២៨ ជំនួយការ ការិយាល័យផែនការប្រតិបត្តិការ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៣-អនុសេនីយ៍ទោ **យាង ឌុទ្ធី** អត្តលេខ ១៩៧០៥៣ ជំនួយការ ការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស ទឹកប្រាក់ចំនួន ៨.០០០ដុល្លារ

១៤-អនុសេនីយ៍ទោ **ឆាង មិន** អត្តលេខ ០៨០៨៣៣ អនុប្រធានស្នាក់ការសន្តិសុខB៨ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៥-អនុសេនីយ៍ទោ **អឿម វ៉ាឌុច** អត្តលេខ ១៩៧១០២ អនុប្រធានស្នាក់ការសន្តិសុខ៦៨១ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

**គ-មេដាយសេរីវឌ្ឍនាជាតិ**

១-វរសេនីយ៍ឯក **ឈៀង សុខុម** អត្តលេខ ០០១១៦៣ មេបញ្ជាការរងនិងជានាយសេនាធិការ កងរាជអាវុធហត្ថខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

២-វរសេនីយ៍ឯក **ឃិត សារឿន** អត្តលេខ ០១២៥១៥ មេបញ្ជាការរងនិងជាប្រធានមន្ទីរស្រាវជ្រាវនិងយុត្តិធម៌ កងរាជអាវុធហត្ថខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

៣-វរសេនីយ៍ឯក **គង់ សុភាព** អត្តលេខ ០០១២៣៥ មេបញ្ជាការរង ទទួលការងារប្រភពកម្លាំងកងរាជអាវុធហត្ថខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

៤-វរសេនីយ៍ឯក **អ៊ឹម មុន្នីរ័ត្ន** អត្តលេខ ០២០៦៨៣ មេបញ្ជាការរងនិងជាប្រធានមន្ទីរភស្តុភារបច្ចេកទេសកងរាជអាវុធហត្ថខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

៥-វរសេនីយ៍ឯក **មាន ទុំ** អត្តលេខ ០១២៥៣៤ មេបញ្ជាការរងទទួលការងារភស្តុភារបច្ចេកទេសកងរាជអាវុធហត្ថខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

៦-វរសេនីយ៍ទោ **សៀម នោរិទ្ធ** អត្តលេខ ០២៣៨៩២ មេបញ្ជាការរងនិងជាប្រធានមន្ទីរព័ត៌មានសន្តិសុខកងរាជអាវុធហត្ថខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

៧-វរសេនីយ៍ទោ **យ៉ាត គារិន** អត្តលេខ ០១០១១៧ មេបញ្ជាការរងនិងជាប្រធានមន្ទីរប្រភពកម្លាំងកងរាជអាវុធហត្ថខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ១.៥០០ ដុល្លារ

៨-វរសេនីយ៍ត្រី **លី ហួត** អត្តលេខ ០៣៧៣២៦ អនុប្រធានមន្ទីរស្រាវជ្រាវនិងយុត្តិធម៌ កងរាជអាវុធហត្ថខេត្តព្រះសីហនុ ទឹកប្រាក់ចំនួន ២.៥០០ ដុល្លារ

៩-អនុសេនីយ៍ឯក **ម៉េង ឫទ្ធិហ៊ីរ** អត្តលេខ ០២០៥៥០ មេបញ្ជាការមូលដ្ឋានកងរាជអាវុធហត្ថក្រុងសៀមរាបខេត្តសៀមរាប ទឹកប្រាក់ចំនួន ៤.០០០ ដុល្លារ

១០-អនុសេនីយ៍ឯក **វ៉ា ម៉ូន** អត្តលេខ ០៤៦៨៦៩ ប្រធានស្នាក់ការសន្តិសុខB៨ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៤.០០០ ដុល្លារ

១១-អនុសេនីយ៍ឯក **ទ្រី សេងឆេង** អត្តលេខ ០៣៦៩៦០ ប្រធានស្នាក់ការសន្តិសុខ អ២០៤ កងរាជអាវុធហត្ថខេត្តឧត្តរមានជ័យ ទឹកប្រាក់ចំនួន ៣.៥៥០ដុល្លារ

១២-អនុសេនីយ៍ទោ **សេខ សុភា** អត្តលេខ ១៩៦៩៨៣ មេបញ្ជាការរងមូលដ្ឋានកងរាជអាវុធហត្ថស្រុកវ៉ារិនខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៣-អនុសេនីយ៍ត្រី **សរ ម៉ិនធឿន** អត្តលេខ ១៩៥៩៧២ ជំនួយការ ការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនកងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៤-អនុសេនីយ៍ត្រី **ឡេង តាំងគួយ** អត្តលេខ ១៦០៩៨១ ជំនួយការ ការិយាល័យផែនការប្រតិបត្តិការកងរាជអាវុធហត្ថខេត្តសៀមរាបទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៥-អនុសេនីយ៍ត្រី **សាយ សេខ** អត្តលេខ ១០៨៩១៩ ជំនួយការ មូលដ្ឋានកងរាជអាវុធហត្ថស្រុកវ៉ារិនខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៦-អនុសេនីយ៍ត្រី **រ័ត្ន ម៉ាន់និត** អត្តលេខ ១០៥៧៨២ អនុប្រធានស្នាក់ការសន្តិសុខ៦៧២ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៧-អនុសេនីយ៍ត្រី **ស្រេខ សុឡី** អត្តលេខ ២១០៦៨៧ អនុប្រធានស្នាក់ការសន្តិសុខ៦៧១ កងរាជអាវុធហត្ថខេត្តសៀមរាប ទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ

១៨-លោកឧញ៉ា **អ៊ឹម មេងជី** នាយកក្រុមហ៊ុន សេង ហ៊ុងហេង ខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ២.៥០០ ដុល្លារ

១៩-លោក **លី ម៉ុម** អគ្គនាយកឱសថ ទឹកប្រាក់ចំនួន ២.៥០០ ដុល្លារ

២០-លោក **លី ហួត** ប្រធានកសិដ្ឋានស្រែប្រាំងស្រុកបារាយ៍ខេត្តកំពង់ធំ ទឹកប្រាក់ចំនួន ២.៥០០ ដុល្លារ

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៤ សរណន

# សារាចរណែនាំ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១២

## I. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបែងចែកកិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ជា ៣ ដំណាក់កាលគឺ (១) *ដំណាក់កាល ទី១:* ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនា ដល់ខែឧសភា (២) *ដំណាក់កាល ទី ២:* ការរៀបចំកញ្ចប់ថវិកាពីខែ មិថុនា ដល់ខែកញ្ញា និង*ដំណាក់កាលទី ៣:* ការអនុម័តថវិកា ពីខែតុលា ដល់ខែធ្នូ ។ ដើម្បីធានាការអនុវត្តច្បាប់នេះ និងដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំពីរគឺ ***សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា*** នៅដើមខែ មេសា សម្រាប់ដំណាក់កាលទី ១ និង ***សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ*** នៅដើមខែមិថុនា សម្រាប់ដំណាក់កាលទី ២ ។ ដូច្នេះសារាចរនេះ គឺជាមគ្គុទ្ទេសក៍ សម្រាប់ណែនាំ និងជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១២-២០១៤ ដល់គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញគ្រប់រាជធានី ខេត្តទាំងអស់ ។

២- ផែនការយុទ្ធសាស្ត្រថវិកាគឺជាឧបករណ៍ និងជាយន្តការដ៏សំខាន់ក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ថវិកា តាមរយៈការជួយតម្រង់ និងជំរុញឱ្យការវិភាជថវិកាចំទិសដៅ ការវិភាជថវិកាបម្រើឱ្យសកម្មភាពអាទិភាព និងការវិភាជថវិកាមានភាពជាក់ស្តែង ដើម្បីសម្រេចរាល់ចំណាយរបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត បម្រើទាំងស្រុង និងសម្រេចឱ្យបាននូវគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពរបស់ក្រសួង-ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពរបស់វិស័យនីមួយៗ សម្រាប់រួមចំណែកសម្រេចឱ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ។ ផែនការយុទ្ធសាស្ត្រថវិកានេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣) ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព និង (៥) ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាព ក្នុងការកំណត់កញ្ចប់ និងការវិភាជថវិកា ។

ដូច្នេះ គឺជាតម្រូវការចាំបាច់ ដែលគ្រប់ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ធ្វើបច្ចុប្បន្នភាព ***ផែនការយុទ្ធសាស្ត្រថវិកា*** ជារៀងរាល់ឆ្នាំ ។

៣- ផែនការយុទ្ធសាស្ត្រថវិកានេះ មិនត្រឹមតែបាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់ ក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការវិភាជ ការប្រើប្រាស់ និងការគ្រប់គ្រងថវិកា ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់សម្រាប់ការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ឱ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ ។ ***ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ អាចប្រព្រឹត្តទៅដោយរលូន និងគ្រប់ជ្រុងជ្រោយ ជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះ តម្រូវឱ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងបញ្ចូលទាំងថវិកាចរន្ត និងថវិកាមូលធន រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ផងនោះ ក្រសួង- ស្ថាប័ននីមួយៗ ត្រូវប្រើប្រាស់ក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុ ឬ/និងគណនេយ្យ នាយកដ្ឋានផែនការ និងអង្គភាពគ្រប់គ្រងគម្រោង*** ។ ក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ក្រសួង- ស្ថាប័ន ដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពិនិត្យ សម្រេច និងចុះហត្ថលេខា ។ ***គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១២- ២០១៤ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ឱ្យបានត្រឹមថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១*** ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេលវេលាគ្រប់គ្រាន់ សម្រាប់ពិនិត្យ និងអាចអញ្ជើញតំណាងក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មកពិគ្រោះ និង សាកសួរព័ត៌មានបន្ថែម ក្នុងករណីចាំបាច់ ។ ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិវិភាជកញ្ចប់ថវិកា ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

### ក. <u>ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច</u>

៤- ជាទូទៅ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំ ២០១០ មានលក្ខណៈល្អប្រសើរ ហើយកំពុងងើបឡើងវិញ តាមទម្រង់ជាអក្សរវេ "V" បន្ទាប់ពីទទួលផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីវិបត្តិកលិយុគហិរញ្ញវត្ថុ អន្តរជាតិ ការធ្លាក់ចុះសេដ្ឋកិច្ចពីព្យុះកេតសាណា និងពីការប្រឈមក្នុងកាតព្វកិច្ចការពារអធិបតេយ្យភាព និង បូរណភាពទឹកដី ក្នុងឆ្នាំ ២០០៨ និង ២០០៩ ។ កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០១០ សម្រេចបាន ៥,៩ % ក្នុងនោះ វិស័យកសិកម្មមានកំណើន ៤% វិស័យឧស្សាហកម្មមានកំណើន ១៣,៥% និងវិស័យសេវាកម្ម មានកំណើន ៣,១% ។

៥- តាមការព្យាករណ៍ដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ ២០១១ នេះអាចនឹងសម្រេចបានក្នុងរង្វង់ជុំវិញ ៦ % ដូចបានគ្រោងទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។ កំណើននេះបានមកពីកំណើនវិស័យកសិកម្មប្រមាណ ៤,១% ដោយសារ

កំណើនដំណាំកៅស៊ូ ដំឡូងមី ជាពិសេសកំណើនផលិតកម្មស្រូវ ដែលជាផ្លែផ្កានៃការអនុវត្តឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ។ វិស័យឧស្សាហកម្មអាចនឹងមានកំណើន ៩,២% បន្ទាប់ពីវិស័យកាត់ដេរបានងើបឡើងវិញ ស្របនឹងការវិនិយោគក្នុងអនុវិស័យផ្គុំដំឡើង និង ការរុករករ៉ែ និងវារីអគ្គិសនីកំពុងចាប់ផ្តើមដំណើរការអាជីវកម្ម ។ កំណើនក្នុងវិស័យសេវាកម្មអាចនឹងសម្រេចបាន ៥,៧% ដែលកំណើននេះ បានមកពីកំណើនអ្នកទេសចរ ការរើបឡើងវិញនៃផ្នែកអចលនវត្ថុ និង ផ្នែកធនាគារនិងហិរញ្ញវត្ថុ នឹងជួយជំរុញការរីកចម្រើនក្នុងវិស័យនេះ ។

៦- កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១២ តាមការព្យាករណ៍ អាចនឹងសម្រេចបានក្នុងរង្វង់ជុំវិញ ៦,៥%។ កំណើនបានមកដោយសារ វិស័យកសិកម្ម អាចនឹងរក្សាកំណើនបាន ៤,២% ក្នុងនោះតម្រូវការកសិផលសម្រាប់ចំណីអាហារមាននិន្នាការកើនឡើងជាពិសេសក្នុងតំបន់អាស៊ី ដែលជាមូលដ្ឋានក្នុងការជំរុញផលិតកម្មស្រូវ និងដំណាំដទៃទៀត ដូចជាដំឡូងមី ស្វាយចន្ទី ពោត ជាដើម ។ ដូចគ្នាដែរ ផលិតកម្មកៅស៊ូនឹងនៅតែបន្តកើនឡើងខ្ពស់ថែមទៀត ខណៈដែលផ្ទៃដីកៅស៊ូដល់ពេលប្រមូលផលបានបន្តកើនឡើង ស្របពេលនឹងតម្លៃកៅស៊ូកើនឡើងជាលំដាប់ ។ វិស័យឧស្សាហកម្ម អាចនឹងមានកំណើន ៩,៤% ដោយរំពឹងថាវិស័យកាត់ដេរនឹងអាចកើនឡើង ១១,២% ដោយការនាំចេញទៅសហគមន៍អឺរ៉ុបអាចនឹងកើនឡើង ក្រោមកម្មវិធី «ទំនិញគ្រប់មុខលើកលែងតែសព្វាវុធ» និងការផ្ទេររោងចក្រមួយចំនួនពីប្រទេសក្នុងតំបន់មកកម្ពុជា ដោយសារបាត់បង់ភាពប្រកួតប្រជែងនៃប្រទេសទាំងនោះក្នុងវិស័យនោះ ។ បន្ថែមលើសនេះទៀត គម្រោងវិនិយោគថ្មីៗមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី ទាំងដើរដោយធ្យូងថ្ម នឹងចាប់ផ្តើមដំណើរការអាជីវកម្ម ស្របពេលនឹងគម្រោងផ្សេងៗទៀត ក្នុងវិស័យរ៉ែ និងឧស្សាហកម្មធុនស្រាលក៏ចាប់ផ្តើមមានសកម្មភាពជាបណ្តើរៗ។ វិស័យសេវាអាចសម្រេចបានកំណើន ៥,៧% ដោយសារតែចំនួនភ្ញៀវទេសចរនឹងបន្តកើនឡើង ពិសេសពីក្នុងតំបន់។ វិស័យហិរញ្ញវត្ថុ អាចនឹងមានសន្ទុះខ្លាំងឡើង ដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចជាទូទៅ ស្របពេលនឹងការបង្កើតទីផ្សារមូលបត្រ ដែលនឹងជួយជំរុញសកម្មភាពហិរញ្ញវត្ថុកាន់តែសកម្ម ក្នុងនោះ រួមទាំងការជំរុញហិរញ្ញប្បទានក្នុងក្របខ័ណ្ឌគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។ វិស័យអចលនវត្ថុ និងសំណង់ ក៏រំពឹងថានឹងងើបឡើងវិញជាបណ្តើរៗ ដោយសារមានកំណើនក្នុងវិស័យខាងលើ ។

៧- អតិផរណានៅកម្ពុជា រងឥទ្ធិពលដោយសារកំណើនតម្លៃម្ហូបអាហារ និងប្រេងឥន្ធនៈយ៉ាងគំហុកចាប់តាំងពីចុងឆ្នាំ ២០០៧ មក ។ ឥទ្ធិពលនេះ បានធ្វើឱ្យអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ២០០៨ ឡើងដល់ ១៩,៧% ។ ដោយសារការឆ្លើយតបដ៏ទាន់ពេលវេលារបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយជាកញ្ចប់ប្រកបដោយប្រសិទ្ធភាព ជាពិសេសការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុដ៏សមស្រប និងប្រុងប្រយ័ត្ន អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ស្ថិតក្នុងកម្រិត -០,៦% នៅឆ្នាំ ២០០៩ និង ៤,០% នៅឆ្នាំ ២០១០ ។ ប៉ុន្តែ ដោយសារអតិផរណាមាននិន្នាការកើនឡើងជាសកល បណ្តាលមកពីការឡើងថ្លៃប្រេង និងម្ហូបអាហារ ថ្លៃវត្ថុធាតុដើម ការបញ្ចេញសាច់ប្រាក់បន្ថែមក្នុងទីផ្សារ ការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសនៅតំបន់អាស៊ី *អត្រាអតិផរណាមធ្យម*ប្រចាំឆ្នាំ ២០១១ នេះអាចនឹងឡើងដល់ ៥,៥% ធៀបនឹងការកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ

២០១១ ដែលកម្រិតត្រឹមតែ ៤,៥% ។ នៅឆ្នាំ ២០១២ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំនឹងកម្រិតក្នុងរង្វង់ជុំវិញ ៥,០% ដោយសារឥទ្ធិពលនេះនឹងនៅតែបន្តមាន ប៉ុន្តែក្នុងល្បឿនយឺតជាងមុន ។

៨- អត្រាប្តូរប្រាក់ មានស្ថិរភាពល្អប្រសើរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងនោះប្រាក់រៀល នៅឆ្នាំ ២០០៩ មានតម្លៃជាមធ្យម ៤១៤៨ រៀល/ដុល្លារ និង មានតម្លៃ ៤១៧៤ រៀល/ដុល្លារ នៅឆ្នាំ ២០១០ និង នៅឆ្នាំ ២០១១ នឹងមានតម្លៃ ៤០៥០ រៀល/ដុល្លារ ។ នៅឆ្នាំ ២០១២ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំរំពឹងថានឹងមានតម្លៃ ៤០៥០ រៀល/ដុល្លារ ដោយសារការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ក្នុងបរិការណ៍នៃការធ្លាក់ចុះតម្លៃប្រាក់ដុល្លារអាមេរិក ។ អត្រាប្តូរប្រាក់នេះ ទាបជាងអត្រាប្តូរប្រាក់ដែលបានកំណត់ចំនួន ៤១០០ រៀល/ដុល្លារ នៅក្នុង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣** » ។

៩- ឱនភាពគណនីចរន្តមាននិន្នាការធ្លាក់ចុះជាលំដាប់គឺពី -១១,៦% នៃផសស នៅឆ្នាំ ២០០៩ ធ្លាក់ចុះមក -១០,៩% នៃផសស ឆ្នាំ ២០១០ ។ ឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះមកត្រឹមតែ -៨,៥% នៅឆ្នាំ ២០១១ និង -៧,៩% នៅឆ្នាំ ២០១២ ។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញ របស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផលនិងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឱ្យការនាំចូលជាបណ្តើរៗ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាល រក្សាអប្បមាទខ្ពស់ ដោយតាមដានជាប្រចាំនូវឥទ្ធិពលនៃថ្លៃប្រេងលើជញ្ជីងពាណិជ្ជកម្ម។ ទុនបម្រុងអន្តរជាតិបានកើនឡើងពី ២,៤ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៩ ដល់ ២,៦៥ ពាន់លានដុល្លារអាមេរិកនៅឆ្នាំ ២០១០ ។ សម្រាប់ឆ្នាំ ២០១១ និង ២០១២ ទុនបម្រុងអាចកើនឡើងដល់ ឬអាចលើសពី ២,៨ ពាន់លានដុល្លារអាមេរិក ដែលអាចធានាបានការនាំចូលប្រមាណជាង ៣ ខែ ។

១០- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ មានគោលបំណងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនប្រកបដោយចីរភាព និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងគ្រប់គ្រងស្ថិរភាពថ្លៃនៅលើទីផ្សារ និងនិរន្តរភាពបំណុលជាទូទៅ ។ **ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅនៃកំណើនផសស ពិត ឱ្យសម្រេចបានក្នុងកម្រិត ៦% នៅឆ្នាំ ២០១១ និង ៦,៥% នៅឆ្នាំ ២០១២ ។ ជាមួយគ្នានេះដែររាជរដ្ឋាភិបាលនឹងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់ ៥,៥% ក្នុងឆ្នាំ ២០១១ និង ៥% ក្នុងឆ្នាំ ២០១២ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធានាឱ្យបានស្ថិរភាពអត្រាប្តូរប្រាក់រៀល ឱ្យស្ថិតនៅក្នុងរង្វង់ជុំវិញ ៤០៥០ រៀល/ដុល្លារ ក្នុងគោលដៅជំរុញបដិដុល្លារូបនីយកម្ម ក្នុងរយៈពេលវែង ចំពោះមុខតាមរយៈការបង្កើនការប្រើប្រាស់ប្រាក់រៀល ។**

## ខ. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

១១- ដោយផ្អែកលើមូលដ្ឋាននៃ «**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២**» និង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣**» គោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានគោលដៅសំខាន់ៗ ដូចតទៅ ÷

- ធានាការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣**

ជាពិសេស ការបន្តជំរុញការអនុវត្ត ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា*** សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ ២០១១-២០១៣ ។
- ធានាការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ដូចជា÷
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកម្ពស់សេវាសាធារណៈនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល និងសុវត្ថិភាពសង្គម ។
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកម្ពស់សកម្មភាពដែលបម្រើឱ្យវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍជនបទ ។
- ធានាបន្តអនុវត្តកម្មវិធីកែទម្រង់ កម្មវិធីអភិវឌ្ឍន៍គ្រប់ការដ្ឋាន និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។
- ធានាការពារគ្រប់ជ្រុងជ្រោយឱ្យបានទាំងស្រុងនូវអធិបតេយ្យភាពនិងបូរណភាពទឹកដី និង កាតព្វកិច្ចធ្វើជា ម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងការបោះឆ្នោតព្រឹទ្ធសភា និងការបោះឆ្នោត ឃុំ-សង្កាត់ ដើម្បីធានាប្រក្រតីភាពនៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មថ្នាក់មូលដ្ឋាននៅកម្ពុជា ។

១២- ដើម្បីឈានសម្រេចគោលដៅខាងលើនេះ រាជរដ្ឋាភិបាលកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម ៈ

- ដើម្បីធានាចីរភាពថវិកាដែលជាគន្លឹះក្នុងការធានាបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដែលគត់មត់ និង មានលក្ខណៈអនុគ្រោះសម្រាប់កំណើន អតិរេកថវិកាចរន្តត្រូវធានាឱ្យបានក្នុងរង្វង់ ១,៧៦% នៃផសស សម្រាប់ឆ្នាំ ២០១១ និង ២,០៨% នៃផសសសម្រាប់ឆ្នាំ ២០១២ ។ ចំណែកឱនភាពថវិកាសរុប នឹងត្រូវកាត់បន្ថយពី -៧,៩៥% នៃផសស នៅឆ្នាំ ២០១០ មកនៅត្រឹម -៦,៣៤% នៃផសស នៅឆ្នាំ ២០១១ និង -៦,០៣% នៃផសស នៅឆ្នាំ ២០១២ ។
- ចំណូលសរុបនៅឆ្នាំ ២០១១ ត្រូវសម្រេចឱ្យបាន ១៣,៣៥% នៃផសស ។ ក្នុងនោះ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវសម្រេចឱ្យបាន ៦,៣១% នៃផសស និងចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវសម្រេចឱ្យបាន ៤,៦៦% នៃផសស ហើយចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន ២,៣៨% នៃផសស ។ ចំណូលសរុបសម្រាប់ឆ្នាំ ២០១២ ត្រូវសម្រេចឱ្យបានស្មើនឹង ១៣,៧៧% នៃផសស ។ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវសម្រេចឱ្យបាន ៦,៥៥% នៃផសស និងចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឱ្យបាន ៤,៩១ % នៃផសស ហើយចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន ២,៣១% នៃផសស ។
- ចំណាយសរុប ត្រូវរក្សាឱ្យនៅត្រឹម ១៩,៦៩% នៃផសស នៅឆ្នាំ ២០១១ ដោយចំណាយចរន្តត្រូវរក្សាឱ្យបានត្រឹម ១១,៤៨% នៃផសស ។ ចំណាយសរុបសម្រាប់ឆ្នាំ ២០១២ ត្រូវរក្សាឱ្យនៅត្រឹម ១៩,៧៩% នៃផសស ដោយចំណាយចរន្តនឹងកម្រិតត្រឹម ១១,៥៨% នៃផសស ដោយក្នុងនោះ កំណើនបៀវត្សមូលដ្ឋាន

សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ចំនួន ២០% ត្រូវបានរក្សាដដែល ។ ជាមួយគ្នានេះដែរ ចំណាយមូលធន នឹងរក្សាស្មើនឹង ៨,២៧% នៃផសស នៅឆ្នាំ ២០១១ និង សម្រាប់ឆ្នាំ ២០១២ ។

១៣- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើនេះ និង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០១២ ត្រូវគ្រោង និងរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម ÷

- បន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- បន្តពង្រឹងការរៀបចំថវិកា ឱ្យកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និងសុក្រឹតភាព តាមរយៈការបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឱ្យបានច្បាស់លាស់ និងសុក្រឹត ការធ្វើសមាហរណកម្មថវិកា និងការបន្តកែលម្អការអនុវត្តថវិកាតាមកម្មវិធី ។
- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈ ការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល- ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងពាក់កណ្តាលឆ្នាំ ការបន្តពង្រឹង ការអនុវត្តវិសហមជ្ឈការលទ្ធកម្មសាធារណៈ រឹតបន្តឹងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និង ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា*** ដែលសម្រេចបាននៅក្នុងជំហានទី១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់សម្រាប់ អនុវត្តកម្មវិធីជំហានទី២ ***គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** និង បណ្តាជំហានបន្តបន្ទាប់ទៀត ។
- បន្តពង្រឹង និងបង្កើនការអនុវត្តប្លង់គណនេយ្យថ្មី និង ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មីប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ ឱ្យកាន់តែសុក្រឹត ព្រមទាំងការត្រួតពិនិត្យផ្ទៃក្នុង និងជាពិសេស ចាប់ផ្តើមកំណត់ និងដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា បរិបទ និងនីតិវិធី អនុវត្តថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលជាសកម្មភាពការងារដំបូង សម្រាប់សម្រេចជំហានទី២ គឺ ***ការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រតាមប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេស ខាងផ្នែកប្រមូលពន្ធដូចជា ការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។
- ពង្រឹងការគ្រប់គ្រងសហគ្រាសសាធារណៈ ពិសេសការបង់ពន្ធ និង ការបង់ចំណែកនៃប្រាក់ចំណេញជូនរដ្ឋ ។
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និង បណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពី

ប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រ សហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ជៀសវាងបេសកកម្មបរទេស ឬការចូលរួមប្រជុំនៅបរទេស ឬការរៀបចំប្រជុំនៅក្នុងប្រទេសដែលពុំសូវចាំបាច់ ការបញ្ឈប់ការទិញសម្ភារៈប្រណិត ការទិញសម្ភារៈថ្មី និងការបោះពុម្ពដែលពុំសូវចាំបាច់ ព្រមទាំងផ្អាកការសាងសង់អគារថ្មី ឬការជួសជុលដែលពុំចាំបាច់ និងមានវិធានការម៉ឺងម៉ាត់ក្នុងកិច្ចលទ្ធកម្មសាធារណៈ ។
- ពង្រឹងការគ្រប់គ្រង និង ការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកអណ្តែត ។

## III. សេចក្តីសន្និដ្ឋាន

១៤- ជារួម នៅក្នុងបរិការណ៍ក្រោយវិបត្តិ សេដ្ឋកិច្ចកម្ពុជា នឹងមានកំណើនល្អ ទោះបីការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកមានលក្ខណៈផុយស្រួយនៅឡើយក្តី ។ ក្នុងបរិការណ៍នេះ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច នឹងត្រូវសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រមាណ ៦% នៅឆ្នាំ ២០១១ និង ៦,៥% នៅឆ្នាំ ២០១២ ដោយរក្សាអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់ដែលអាចគ្រប់គ្រងបាន ពោលគឺក្នុង រង្វង់ ៥% ក្នុងមួយឆ្នាំ ។ ជាមួយគ្នានេះដែរ អតិរេកចរន្តត្រូវរក្សាឱ្យស្ថិតក្នុង ១,៧៦% នៃ ផសស នៅក្នុងឆ្នាំ ២០១១ និង ២,០៨ % នៅ ក្នុងឆ្នាំ ២០១២ ដែលក្នុងនោះ ឱនភាពថវិកាសរុប នឹងត្រូវកាត់បន្ថយមកត្រឹម -៦,០៣% នៃ ផសស ហើយនឹងអាចទាបជាងនេះជាលំដាប់នៅក្នុងរយៈពេលមធ្យមខាងមុខ ។

១៥- ការកំណត់គោលដៅ នៅក្នុងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ក្របខ័ណ្ឌគោល-នយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ គឺជាកត្តាគន្លឹះ ក្នុងការធានាបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងចីរភាព និងស្ថិរភាពនៃថវិកា ដែលអាចឱ្យរាជរដ្ឋាភិបាលឈានទៅសម្រេចឱ្យបាននូវគោលដៅចម្បងនៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** គឺ ***«ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងរយៈពេលវែង មានអត្រាខ្ពស់ប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតត្រឹមលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ»*** និង ***«ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានលើស ១% ក្នុងមួយឆ្នាំ និង ការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និង សមភាពយេនឌ័រ»*** ព្រមទាំងឈានទៅសម្រេចបាននូវគោលដៅសហសវត្សរ៍កម្ពុជា ទាំង ៩ ។ ទន្ទឹមនឹងនេះដែរ ក្របខ័ណ្ឌគោលនយោបាយខាងលើ ក៏បានឆ្លុះបញ្ចាំងពីភាពចាំបាច់ក្នុងការខិតខំប្រឹងប្រែងបន្ថែម ក្នុងការកៀរគរចំណូល ទាំងចំណូលសារពើពន្ធ ទាំងចំណូលមិនមែនសារពើពន្ធ និង ការធ្វើវិចារណកម្មចំណាយឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ជាងមុន ។

## IV. សេចក្តីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១៦- ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១១-២០១៣ របស់ខ្លួន និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត នីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃលើការអនុវត្តកន្លងមក ដើម្បីកែសម្រួល និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១២-២០១៤ ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។ គំរូផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ ២០១២-២០១៤ ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នេះរួមមាន ៦ ផ្នែកគឺៈ

***ផ្នែកទី ១ៈ សេចក្តីផ្តើម*** គឺជាការរៀបរាប់អំពីមុខងារ និងភារកិច្ចរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អំពីស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាក្នុងឆ្នាំកន្លងមក និងឆ្នាំកំពុងអនុវត្ត និងអំពីការចូលរួមចំណែកក្នុងការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ដើម្បីសម្រេចបាននូវគោលនយោបាយរួម របស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ។

***ផ្នែកទី ២ៈ គោលបំណងគោលនយោបាយ*** គឺជាគោលបំណងគោលនយោបាយរយៈពេលមធ្យម (ពី ៣ ទៅ ៥ ឆ្នាំ) ដែលត្រូវបានកំណត់ដោយក្រសួង-ស្ថាប័ន ហើយដែលត្រូវបានរៀបចំនៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ដែលជាយុទ្ធសាស្ត្រគោលនយោបាយដើម្បីអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់កម្រិតជីវភាព របស់ប្រជាពលរដ្ឋ ។

***ផ្នែកទី ៣ៈ កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព*** គឺជាកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២ ខាងលើ ។ ការកំណត់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺរួមមានទាំង កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពសម្រាប់ថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដូចក្នុងតារាងទី ៣.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

***ផ្នែកទី ៤ៈ ការកំណត់សូចនាករ និងគោលដៅសូចនាករ*** គឺជាការកំណត់សូចនាករ និង គោលដៅសូចនាកររបស់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ សម្រាប់តាមដាន និងវាស់លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ ដែលបានរៀបចំដើម្បីសម្រេចបាននូវគោលដៅនៃគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលបានកំណត់ ។ សូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុដែលត្រូវបានជ្រើសរើស បញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន កំណត់គោលដៅនៃលទ្ធផលក្នុងឆ្នាំនីមួយៗ និងកំណត់គោលដៅនៃលទ្ធផលចុងក្រោយ ដូចក្នុងតារាងទី ៤.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយសារាចរណែនាំនេះ ។

***ផ្នែកទី ៥ៈ ការកំណត់ធនធាន*** គឺជាការគ្រោងតម្រូវការចំណាយ និង ចំណូលសម្រាប់រយៈពេល ៣ ឆ្នាំ (២០១២-២០១៤) ហើយការគ្រោងនេះ គឺត្រូវគិតបញ្ចូលទាំងថវិកាជាតិ និង ថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ។ ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ (២០១២-២០១៤) ទៅតាមកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន

រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ ដូចក្នុងតារាងទី ៥.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយនឹងសារាចរណែនាំនេះ ។ ការគ្រោងចំណូល គឺជាការគ្រោងចំណូលសម្រាប់រយៈពេល ៣ ឆ្នាំ (២០១២-២០១៤) ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និង បទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោល-នយោបាយ និងវិធានការថ្មីដែលគ្រោងនឹងដាក់ឱ្យអនុវត្ត ។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលគ្រប់ប្រភេទនៃចំណូលទាំងអស់ រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត និង ចំណូលដែលបានមកពីដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួង-ស្ថាប័ន ដូចក្នុងតារាងទី ៥.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយនឹងសារាចរណែនាំនេះ។

***ផ្នែកទី ៦: សេចក្តីសន្និដ្ឋាន*** គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១២ និងការលើកទិសដៅ ក៏ដូចជាវិធានការ ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១២ ។

១៧- ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណី ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត មានចំណុច ណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"***ដើម្បីជូនជ្រាប***"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

"***ដើម្បីអនុវត្ត***"

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia

Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

Ministry of Industry, Mines and Energy

លេខ : ២៧៣ ឧរថ-កសឧ-ប្រក-

**លិខិតចូល**

ថ្ងៃទី ២១ ខែមេសា ឆ្នាំ 2011

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីគំនូរបន្ទាញនៃសៀវភៅបន្ថែម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្របក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ស្តីពីការតម្លើងការិយាល័យកម្មសិទ្ធិឧស្សាហកម្មនៃនាយកដ្ឋានបច្ចេកទេស ទៅជានាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ៤៨៧ ឧរថ.បល.ប្រក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- តាមការចាំបាច់របស់ក្រសួង

៥

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ ៨៥៥-២៣-៤២៨២៦៣

45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- ការកំណត់លក្ខណៈរបស់ប្រកាស**

ប្រកាសនេះត្រូវបានចាត់ទុកជាបទបញ្ញាសម្រាប់ការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម នៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីការពារកម្មសិទ្ធិបញ្ញារបស់អ្នកបង្កើតស្នាដៃតក្កកម្មខាងផ្នែកគំនូរបង្ហាញនៃសៀគ្វីបង្រួម ។

**ប្រការ ២.- ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មដែលជានាយកដ្ឋានទទួលបន្ទុកចុះបញ្ជី មានភារកិច្ចទទួលធ្វើការពិនិត្យពាក្យសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម ធ្វើការចុះបញ្ជី និងគ្រប់គ្រងការចុះបញ្ជីនេះឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី ២

## និយមន័យ និង ការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម

**ប្រការ ៣.- និយមន័យ**

គំនូរបង្ហាញ សៀគ្វីបង្រួម ត្រូវបានកំណត់និយមន័យដូចខាងក្រោម ៖

១- **គំនូរបង្ហាញ** គឺការរៀបចំជាទម្រង់បីវិមាត្រនៃធាតុដែលយ៉ាងហោចណាស់មានធាតុមួយជាធាតុសកម្ម ហើយភ្ជាប់ការទំនាក់ទំនងគ្នាទៅវិញទៅមកនៃធាតុមួយ ឬនៃធាតុមួយចំនួន ឬទាំងអស់នៃសៀគ្វីបង្រួម ឬការរៀបចំទម្រង់បីវិមាត្រនោះដែលបានរៀបចំឡើងសម្រាប់សៀគ្វីបង្រួមមានគោលបំណងសម្រាប់ផលិត ។

២- **សៀគ្វីបង្រួម** គឺជាផលិតផលមួយក្នុងទម្រង់ជាផលិតផលសម្រេច ឬពាក់កណ្តាលសម្រេចដែលក្នុងចំណោមធាតុជាច្រើន ដែលបង្កើតផលិតផលនោះដែលយ៉ាងហោចណាស់មានធាតុមួយជាធាតុសកម្ម ហើយបានបង្កើតឡើងនូវការភ្ជាប់គ្នាទៅវិញទៅមកនៃធាតុមួយចំនួន ឬទាំងអស់ដោយរួមបញ្ចូលគ្នានៅក្នុង ឬនៅលើវត្ថុមួយបន្ទះហើយមានគោលបំណងដំណើរការមុខងារផ្នែកអេឡិចត្រូនិច ។

**ប្រការ ៤.- អ្នកដាក់ពាក្យសុំ**

អ្នកដាក់ពាក្យសុំអាចស្នើសុំការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមតាមការស្ម័គ្រចិត្ត ។

**ប្រការ ៥.- គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលអាចសុំចុះបញ្ជីបាន**

គំនូរបង្ហាញនៃសៀគ្វីបង្រួមអាចសុំចុះបញ្ជីបាន ប្រសិនបើគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះពុំទាន់ត្រូវបានយកទៅធ្វើអាជីវកម្មតាមទ្រង់ទ្រាយពាណិជ្ជកម្ម ឬក៏បានធ្វើអាជីវកម្មតាមទ្រង់ទ្រាយពាណិជ្ជកម្ម នៅទីកន្លែងណាមួយនៅលើពិភពលោកក្នុងរយៈពេលមិនលើសពី ២(ពីរ)ឆ្នាំ ។

**ប្រការ ៦.- លក្ខខណ្ឌនៃការចុះបញ្ជី**

គំនូរបង្ហាញនៃសៀគ្វីបង្រួមអាចចុះបញ្ជីបានប្រសិនបើគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះថ្មី ។

**ប្រការ ៧.- ភាពថ្មី**

គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលអាចចាត់ទុកថាថ្មីបាន លុះត្រាតែគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះជាលទ្ធផលនៃការខិតខំប្រឹងប្រែងខាងប្រាជ្ញាផ្ទាល់របស់អ្នកបង្កើត និងដែលមិនមែនជាការងារសាមញ្ញធម្មតានៅក្នុងចំណោមអ្នកបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួម និងនៅក្នុងចំណោមអ្នកផលិតសៀគ្វីបង្រួមទាំងឡាយ នៅពេលដែលបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះឡើង ។

**ប្រការ ៨.- សិទ្ធិចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួម**

សិទ្ធិចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួមមានដូចខាងក្រោម :

១- សិទ្ធិចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួម គឺជាសិទ្ធិរបស់អ្នកបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។

២- សិទ្ធិនេះអាចប្រគល់ ឬផ្ទេរទៅឱ្យបុគ្គលដទៃដើម្បីស្នងជំនួសបាន ។

៣- ក្នុងករណីមានបុគ្គលច្រើននាក់បានបង្កើតគំនូរបង្ហាញនៃសៀគ្វីបង្រួមរួមគ្នា សិទ្ធិជាម្ចាស់នៃគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះត្រូវតែជាសិទ្ធិរួមគ្នានៃបុគ្គលទាំងឡាយនោះ ។

**ប្រការ ៩.- វិសាលភាពនៃការការពារ**

ការអនុវត្តសកម្មភាពដូចខាងក្រោមនេះ គឺជាសកម្មភាពមិនស្របច្បាប់ប្រសិនបើការអនុវត្តសកម្មភាពនោះពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិរួមមាន :

១- ការចម្លងតាមគំនូរបង្ហាញនៃសៀគ្វីបង្រួមទាំងស្រុង ឬផ្នែកណាមួយនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានការពារដូចខាងលើ ទោះបីបានរួមបញ្ចូលទៅក្នុងសៀគ្វីបង្រួម ឬមិនបានរួមបញ្ចូល លើកលែងតែការចម្លងតាមផ្នែកណាមួយដែលផ្នែកនោះ មិនសមស្របតាមលក្ខខណ្ឌនៃភាពថ្មីដូចមានចែងនៅ

ក្នុងប្រការ ៧ នៃប្រកាសនេះ ។

២.ការនាំចូល ការលក់ ឬការបែងចែកសម្រាប់ធ្វើពាណិជ្ជកម្មនូវសៀគ្វីបង្រួម ដែលបានការពាររួចហើយដោយគំនូរបង្ហាញនៃសៀគ្វីបង្រួម ឬសម្ភារៈដែលបង្កើតឡើងដោយមានការរួមបញ្ចូលនូវសៀគ្វីបង្រួមខាងលើ ដោយបុគ្គលដទៃក្រៅពីម្ចាស់សិទ្ធិត្រូវសុំការអនុញ្ញាតពីម្ចាស់សិទ្ធិ ។

**ប្រការ ១០.- ការលើកលែងពីអានុភាពនៃការការពារ**

អានុភាពនៃការការពារនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមមិនអនុវត្តចំពោះសកម្មភាពដូចខាងក្រោម :

ក. ការចម្លងតាមគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានការពាររួចហើយ សម្រាប់បម្រើគោលបំណងផ្ទាល់ខ្លួន ឬបម្រើគោលបំណងសម្រាប់តែធ្វើការវាយតម្លៃ ការវិភាគ ការសិក្សា ស្រាវជ្រាវ ឬការបង្រៀនតែប៉ុណ្ណោះ ។

ខ. ការរួមបញ្ចូលនៅក្នុងសៀគ្វីបង្រួមនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានបង្កើតឡើងដោយឈរលើមូលដ្ឋានគ្រឹះនៃការវិភាគទាំងនេះ ឬការវាយតម្លៃហើយដែលគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះមានភាពថ្មីស្របតាមប្រការ ៥ នៃប្រកាសនេះ ឬការអនុវត្តនូវសកម្មភាពណាមួយចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួម ដោយយោងតាមប្រការ ៧ នៃប្រកាសនេះ ។

គ. ការអនុវត្តសកម្មភាពណាមួយនៃសកម្មភាពទាំងឡាយដូចមានចែងនៅក្នុងចំណុច ២ នៃប្រការ ៩ នៃប្រកាសនេះចំពោះគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានការពាររួចហើយ ឬចំពោះសៀគ្វីបង្រួមដែលត្រូវបានរួមបញ្ចូលជាមួយគំនូរបង្ហាញនៃសៀគ្វី-បង្រួម ហើយដែលបានដាក់នៅលើទីផ្សារដោយម្ចាស់សិទ្ធិ ឬដោយមានការយល់ព្រមពីម្ចាស់សិទ្ធិនោះ ។

**ប្រការ ១១.- រយៈពេលនៃការការពារ**

ការការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវមានរយៈពេល ១០(ដប់)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមកិច្ចការពារ ។

ការចាប់ផ្តើមកិច្ចការពារត្រូវគិត :

ក. ចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី ប្រសិនបើគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះមិនទាន់បានធ្វើអាជីវកម្ម ពាណិជ្ជកម្មពីមុនមកនៅឡើយនៅទីកន្លែងណាមួយ ។

ខ. ចាប់ពីកាលបរិច្ឆេទធ្វើអាជីវកម្ម ពាណិជ្ជកម្មលើកដំបូងនៃគំនូរបង្ហាញ

នៃសៀគ្វីបង្រួមនោះនៅទីកន្លែងមួយដោយម្ចាស់សិទ្ធិ ឬដោយមានការយល់ព្រមពីម្ចាស់សិទ្ធិក្នុងរយៈពេលអនុញ្ញាតអាចសុំចុះបញ្ជីបានដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ ។

**ប្រការ ១២.- លក្ខខណ្ឌតម្រូវនៃសំណុំលិខិតស្នើសុំ**

លក្ខខណ្ឌតម្រូវនៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម មានដូចខាងក្រោម :

១- សំណុំលិខិតស្នើសុំចុះបញ្ជីការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវដាក់នៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។ គំនូរបង្ហាញនៃសៀគ្វីបង្រួមនីមួយៗត្រូវតែធ្វើសំណុំលិខិតស្នើសុំដោយឡែកៗពីគ្នា ។

២- សំណុំលិខិតស្នើសុំត្រូវ :

ក- មានពាក្យសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមដូចមាន ជូនភ្ជាប់ជាមួយ **ឧបសម្ព័ន្ធ** និងមានអធិប្បាយដោយសង្ខេប និងច្បាស់លាស់អំពីគំនូរបង្ហាញនៃសៀគ្វី-បង្រួមនោះ ។

ខ- បញ្ជាក់អំពីឈ្មោះ អសយដ្ឋាន សញ្ជាតិ និងអសយដ្ឋានស្នាក់នៅរបស់អ្នកដាក់ពាក្យសុំ ។

គ- ភ្ជាប់មកជាមួយនូវឯកសារចម្លង ឬគំនូរបង្ហាញនោះព្រមជាមួយនឹងព័ត៌មានបញ្ជាក់អំពីមុខងារអេឡិចត្រូនិចដែលសៀគ្វីបង្រួមនឹងយកទៅអនុវត្ត និងលិខិតប្រគល់សិទ្ធិប្រសិនបើមានការចាត់តាំងតំណាងរបស់អ្នកដាក់ពាក្យសុំ ។

ឃ- បញ្ជាក់អំពីកាលបរិច្ឆេទធ្វើអាជីវកម្ម ពាណិជ្ជកម្មលើកដំបូងនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមនៅទីកន្លែងណាមួយនៅលើពិភពលោក ឬបញ្ជាក់ថាការធ្វើអាជីវកម្មនោះមិនទាន់ចាប់ផ្តើមនៅឡើយទេ ។

ង- ព័ត៌មានចាំបាច់ផ្សេងទៀតតាមការស្នើសុំរបស់មន្ត្រីកាន់កាប់បញ្ជី ។

**ប្រការ ១៣.- ការចុះកាលបរិច្ឆេទសុំចុះបញ្ជី**

ក្នុងករណីសំណុំលិខិតស្នើសុំមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃប្រការ ១២ នៃប្រកាសនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីកំហុសដែលមាន និងអញ្ជើញអ្នកដាក់ពាក្យសុំឱ្យមកកែកំហុសទាំងនោះក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ ។ ប្រសិនបើកំហុសទាំងនោះបានកែតម្រូវតាមពេលវេលាកំណត់រួច ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវតែចុះនៅថ្ងៃដែល ទទួលការកែតម្រូវនោះ កាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំឱ្យតែនៅពេលដែលទទួល នោះសំណុំលិខិតស្នើសុំមានគំនូរបង្ហាញ និងបញ្ជាក់អំពីការស្នើសុំចុះបញ្ជី

គំនូរបង្ហាញនៃសៀគ្វីបង្រួម និងបញ្ជាក់ឱ្យដឹងនូវអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំហើយ និងមានភ្ជាប់មកជាមួយនូវឯកសារចម្លង ឬគំនូរបង្ហាញនៃគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។ មន្ត្រីកាន់កាប់បញ្ជីត្រូវកំណត់នូវកាលបរិច្ឆេទសុំចុះបញ្ជី និងផ្តល់ព័ត៌មាននេះឱ្យអ្នកដាក់ពាក្យសុំបានដឹង ។ ប្រសិនបើកំហុសទាំងឡាយមិនបានធ្វើការកែលំអតាមពេលវេលាកំណត់ទេនោះ សំណុំលិខិតស្នើសុំនោះ ត្រូវចាត់ទុកថាមិនបានយកមកដាក់ឡើយ ។

**ប្រការ ១៤.- ការបង់កម្រៃសម្រាប់ចុះបញ្ជី**

សំណុំលិខិតស្នើសុំចុះបញ្ជីការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមនីមួយៗ ត្រូវផ្អែកលើការបង់កម្រៃតាមការកំណត់នៃប្រកាសរួមរបស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រសិនបើមិនបានមកបង់កម្រៃក្នុងការសុំចុះបញ្ជីតាមកាលកំណត់ទេ សំណុំលិខិតស្នើសុំនោះត្រូវបានចាត់ទុកថាមិនបានយកមកដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជីឡើយ ។

**ប្រការ ១៥.- ការបោះពុម្ពផ្សាយ ការប្តឹងជំទាស់ ការចុះបញ្ជី និងបញ្ជី**

ការបោះពុម្ពផ្សាយ ការប្តឹងជំទាស់ ការចុះបញ្ជី និងបញ្ជីសម្រាប់គំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវអនុវត្តដូចខាងក្រោម :

១- ក្នុងករណីដែលសំណុំលិខិតស្នើសុំបំពេញត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃប្រការ ១២ និង ១៤ នៃប្រកាសនេះរួច ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវផ្សព្វផ្សាយព័ត៌មានចាំបាច់នៃសំណុំលិខិតស្នើសុំនោះនៅក្នុងព្រឹត្តិបត្រផ្លូវការមុនពេលចុះបញ្ជី ។

២- បុគ្គលដែលមានការពាក់ព័ន្ធអាចជូនដំណឹងទៅ មន្ត្រីកាន់កាប់បញ្ជីអំពីការជំទាស់របស់ខ្លួនចំពោះការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមតាមបែបបទដែលបានកំណត់ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមលក្ខខណ្ឌណាមួយនៃ ប្រការ ៥, ៦, ៧, និង បទបញ្ញាពាក់ព័ន្ធក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃបន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៣- ក្នុងករណីមានការជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់នូវព័ត៌មានជំទាស់ទៅអ្នកដាក់ពាក្យសុំចុះបញ្ជីតាមពេលវេលា ។ បន្ទាប់មកអ្នកស្នើសុំចុះបញ្ជីត្រូវផ្តល់ចម្លើយបញ្ជាក់ដោយផ្អែកលើមូលដ្ឋានទាំងឡាយ សម្រាប់ការចុះបញ្ជីរបស់ខ្លួនជូនមន្ត្រីកាន់កាប់បញ្ជីទៅតាមរយៈពេលដែលកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានឆ្លើយតបតាមការកំណត់នោះទេត្រូវចាត់ទុកថា អ្នកដាក់ពាក្យសុំនោះបានបោះបង់ចោលការសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមរបស់ខ្លួន ។

៤- ប្រសិនបើអ្នកដាក់ពាក្យសុំផ្តល់ចម្លើយបដិសេធទៅនឹងការជំទាស់នោះ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្តឹងជំទាស់ ។ ប្រសិនបើភាគីម្ខាង /-

ឬភាគីទាំងសងខាងមានបំណងចង់ឱ្យមានសវនាការមន្ត្រីកាន់កាប់បញ្ជី ត្រូវរៀបចំឱ្យមានសវនាការនោះ ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាង និងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជីត្រូវសម្រេចថា គំនូរបង្ហាញនៃសៀគ្វីបង្រួមអាចដំណើរការចុះបញ្ជីបាន ឬ បដិសេធការចុះបញ្ជី ។

**៥.** ប្រសិនបើគ្មានការជំទាស់រយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការនោះទេមន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វី-បង្រួមនោះ

**៦.** នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មត្រូវមានបញ្ជីសម្រាប់គំនូរបង្ហាញនៃសៀគ្វី-បង្រួម ។ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាគំនូរបង្ហាញនៃសៀគ្វីបង្រួម ដែលបានចុះបញ្ជីនៅក្នុងបញ្ជីនេះនូវព័ត៌មានដូចខាងក្រោម :

- លេខ
- ចំណងជើង
- កាលបរិច្ឆេទទទួលពាក្យសុំ
- កាលបរិច្ឆេទសុំចុះបញ្ជី
- កាលបរិច្ឆេទលើកដំបូងក្នុងការយកគំនូរបង្ហាញនៃសៀគ្វីបង្រួមទៅធ្វើអាជីវកម្មនៅទីកន្លែងណាមួយនៅលើពិភពលោកប្រសិនបើមាន ។
- ឈ្មោះ និងអសយដ្ឋាន របស់ម្ចាស់សិទ្ធិ និង
- ចំណុចសំខាន់ៗផ្សេងទៀតដែលចាំបាច់ ។

**ប្រការ ១៦.- មោឃភាព**

ចំពោះមោឃភាព ត្រូវអនុវត្តដូចខាងក្រោម :

**១.** បុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំឱ្យទុកជាមោឃៈនូវការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមចំពោះមូលហេតុដូចខាងក្រោម :

**ក.** គំនូរបង្ហាញនៃសៀគ្វីបង្រួមមិនត្រូវបានការពារនៅក្រោមប្រការ ៥, ៦, ៧ នៃប្រកាសនេះ ។

**ខ.** ម្ចាស់សិទ្ធិពុំមានសិទ្ធិចំពោះការការពារនៅក្រោមប្រកាសនេះ ។

**គ.** ក្នុងករណីដែលគំនូរបង្ហាញនៃសៀគ្វីបង្រួម ត្រូវបានយកទៅធ្វើអាជីវកម្ម ពាណិជ្ជកម្មនៅទីកន្លែងណាមួយនៅលើពិភពលោកមុនការដាក់សំណុំលិខិតស្នើសុំចុះបញ្ជី ហើយសំណុំលិខិតស្នើសុំនោះពុំបានយកមកដាក់ត្រឹមត្រូវតាមពេលវេលាកំណត់ដូចមាន

ចែងក្នុងប្រការ ៥ នៃ ប្រកាសនេះ ។

២- ក្នុងករណីដែលមូលហេតុនៃមោឃភាពប៉ះពាល់តែមួយផ្នែក នៃគំនូរបង្ហាញនៃសៀគ្វីបង្រួមទេនោះ គឺផ្នែកនោះឯងតែប៉ុណ្ណោះដែលត្រូវបានចាត់ទុកជាមោឃៈ ។

៣- សំណើសុំចាត់ទុកជាមោឃៈនូវការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវតែសរសេរជាលាយ លក្ខណ៍អក្សរហើយដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជីដើម្បីពិនិត្យ និងសម្រេច ។ សំណើសុំចាត់ទុកជាមោឃៈ ត្រូវមានបញ្ជាក់អំពីមូលហេតុដែលធ្វើជាមូលដ្ឋានក្នុងការស្នើសុំឱ្យចាត់ទុកជាមោឃៈចំពោះការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។

៤- គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានចុះបញ្ជីរួចហើយ ឬផ្នែករបស់គំនូរបង្ហាញនៃសៀគ្វីបង្រួមដែលត្រូវបានចាត់ទុកជាមោឃៈនោះ ត្រូវអស់សុពលភាពចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃកិច្ចការពារគំនូរបង្ហាញនៃសៀគ្វីបង្រួមនោះ ។

**ប្រការ ១៧.- ភ្នាក់ងារ**

ភ្នាក់ងារធ្វើជាតំណាងសម្រាប់អ្នកដាក់ពាក្យសុំចុះបញ្ជី គំនូរបង្ហាញនៃសៀគ្វីបង្រួមត្រូវអនុវត្តដូចខាងក្រោម :

១- ក្នុងករណីអ្នកដាក់ពាក្យសុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកដាក់ពាក្យសុំនោះអាចដាក់ពាក្យសុំដោយខ្លួនឯង ឬអាចចាត់ភ្នាក់ងារជាតំណាងសម្រាប់ដាក់ពាក្យសុំបាន និងដែលបានបំពេញតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ ។

២- ក្នុងករណីអ្នកដាក់ពាក្យសុំមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់នៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកដាក់ពាក្យសុំនោះត្រូវមានតំណាងភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលបានបំពេញតាមលក្ខខណ្ឌតម្រូវទាំងឡាយដែលបានកំណត់ ។

**ប្រការ ១៨.- ការរំលោភបំពាន**

ការអនុវត្តសកម្មភាពណាមួយដែលមិនស្របនឹងប្រការ ៨ នៃប្រកាសនេះត្រូវចាត់ទុកវាជាការរំលោភបំពាន ។

**ប្រការ ១៩.- ការដោះស្រាយវិវាទ**

ការដោះស្រាយទំនាស់ត្រូវអនុវត្តដូចខាងក្រោម :

